សម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា
Cambodian Journalists Alliance

# ខេមបូចាព្រួយបារម្ភយ៉ាងខ្លាំងចំពោះការសម្រេចរបស់តុលាការលើករណី លោក សុខ ឧត្តម

ភ្នំពេញ ថ្ងៃទី ២២ ខែធ្នូ ឆ្នាំ ២០២០ - សម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (ហៅកាត់ថា ខេមបូចា) ព្រួយបារម្ភយ៉ាងខ្លាំងចំពោះការសម្រេចរបស់តុលាការដែលផ្តន្ទាទោសលោក សុខ ឧត្តម ម្ចាស់ស្ថានីយ៍វិទ្យុ និង គេហទំព័ររិទ្ធិសែន ឱ្យជាប់ពន្ធនាគាររយៈពេល២០ខែ និងពិន័យជាប្រាក់ចំនួន២០លានរៀល។

នៅព្រឹកថ្ងៃទី ២២ ខែធ្នូនេះ សាលាដំបូងខេត្តកំពង់ឆ្នាំងបានផ្តន្ទាទោសលោក សុខ ឧត្តម ម្ចាស់ស្ថានីយ៍វិទ្យុ និង គេហទំព័ររិទ្ធិសែន ឱ្យជាប់ពន្ធនាគាររយៈពេល ២០ខែ និងពិន័យជាប្រាក់ចំនួន២០លានរៀលដល់ដើមបណ្តឹងឈ្មោះ នូ សំរិទ្ធ មានតួនាទីជាមេបញ្ជាការរងតំបន់ប្រតិបត្តិការសឹករងខេត្តកំពង់ឆ្នាំង ។ លោកអ៊ី ថាវរៈ ចៅក្រមជំនុំជម្រះបានអានការសម្រេចផ្តន្ទាទោសលោក សុខ ឧត្តម ដោយបញ្ជាក់ថាលោក សុខ ឧត្តមត្រូវផ្តន្ទាទោសតាមមាត្រាលេខ ៤៩៥នៃក្រមព្រហ្មទណ្ឌ។

លោក សុខ ឧត្តម ត្រូវបានអាជ្ញាធរចាប់ខ្លួនកាលពីថ្ងៃទី ១៣ ខែឧសភា និងត្រូវបានឃុំខ្លួនកាលពីថ្ងៃទី ១៥ ខែឧសភា ឆ្នាំ ២០២០នៅពន្ធនាគារខេត្តកំពង់ឆ្នាំង បន្ទាប់ពីលោកបានផ្សាយបន្តផ្ទាល់ពីជម្លោះដីធ្លីរវាងប្រជាពលរដ្ឋ និងមន្ត្រីយោធានៅក្នុងមូលដ្ឋានឃុំជាប ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំងកាលពីថ្ងៃទី ១២ ខែឧសភា ឆ្នាំ២០២០កន្លងទៅ ជាមួយនឹងក្រុមអ្នកសារព័ត៌មានមកពីស្ថាប័នសារព័ត៌មានផ្សេងៗទៀតជាច្រើន។ លោកត្រូវបានចោទប្រកាន់ពីបទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍។

ភ្លាមៗបន្ទាប់ពីការប្រកាសសាលក្រម លោកសុខ ឧត្តម បានសម្តែងនូវការខកចិត្តជាខ្លាំងដោយលោកមានប្រសាសន៍ថា វាអយុត្តិធម៌ខ្លាំងណាស់សម្រាប់លោកហើយលោកនឹងប្តឹងឧទ្ធរណ៍។

នាយកប្រតិបត្តិសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (ខេមបូចា) លោក ណុប វី មានប្រសាសន៍ថា៖ «ការសម្រេចឲ្យលោក សុខ ឧត្តម មានទោស គឺជាការបង្ហាញថា អ្នកសារព័ត៌មានដែលហ៊ានផ្សព្វផ្សាយ និងរាយការណ៍ព័ត៌មាន ដែលប៉ះពាល់ដល់ផលប្រយោជន៍របស់មន្ត្រីយោធា

និងអ្នកមានអំណាច គឺនៅតែទទួលរងការធ្វើទុក្ខបុកម្នេញតាមរយៈប្រព័ន្ធតុលាការដែលប្រើច្បាប់ព្រហ្មទណ្ឌជាជាងប្រើប្រាស់ច្បាប់ស្តីពីរបបសារព័ត៌មាន។ យើងបារម្ភថា យន្តការតាមដាន និងជំរុញយុត្តិធម៌សង្គមនឹងមិនត្រូវបានពង្រឹង»។

ខេមបូចាដែលមានសមាជិក-សមាជិកា និងក្រុមប្រឹក្សាភិបាលជាអ្នកសារព័ត៌មានប្រមាណ ១០០នាក់ សូមអំពាវនាវដល់តុលាការឱ្យពិចារណាឡើងវិញចំពោះការសម្រេចក្តីករណីលោក សុខ ឧត្តម និង បញ្ឈប់ជាបន្ទាន់នូវការប្រើប្រាស់ក្រមព្រហ្មទណ្ឌមកលើអ្នកសារព័ត៌មាន ដើម្បីធានាថា អ្នកសារព័ត៌មានគ្រប់រូបអាចអនុវត្តសិទ្ធិសេរីភាពក្នុងការរាយការណ៍ព័ត៌មានដោយមិនមានភាពភ័យខ្លាច ហើយធានាថា រដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព៕

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖
លោក ណុប វី នាយកប្រតិបត្តិសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (ខេមបូចា)
ទូរសព្ទលេខ៖ ០១២ ៥១៩ ២៦១
អ៊ីមែល៖ ed@camboja.net